**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមហ៊ុនតាណាកា ហ្វ័រសាយថ៍(ខេមបូឌា)អ៊ីន
អាស័យដ្ឋាន តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ
ឡូត P2-090 ភូមិបឹងធំ សង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញ

ថ្ងៃច័ន្ទ១៣កើតខែពិសាខឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ថ្ងៃទី04ខែឧសភាឆ្នាំ២០២០

លេខ...............

**<u>កិច្ចព្រមព្រៀងរវៀងក្រុមហ៊ុននឹងប្រតិភូបុគ្គលិក</u>**
**<u>ស្ដីអំពី</u>**
**<u>ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិកកំឡុងពេលរាតត្បាត់ជំងឺកូវីត ១៩</u>**

ដោយយោងតាមកំណត់ហេតុដែលបានធ្វើឡើង នៅថ្ងៃពុធ៨កើតខែពិសាខឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ដែលត្រូវនឹងថ្ងៃទី២៩ខែមេសាឆ្នាំ២០២០នៅវេលា ម៉ោង១២នឹង២៥នាទី សហគ្រាសតាណាកា ហ្វ័រសាយថ៍(ខេមបូឌា)អ៊ីនបានធ្វើកិច្ចប្រជុំមួយជានឹងតំណាងកម្មករនិយោជិក មានប្រតិភូបុគ្គលិកនឹងកម្មករនិយោជិកទាំងអស់សរុប ៨៨នាក់។ក្នុងនោះផងដែរ តំណាងសហគ្រាសបានរៀបរាប់ពីមូលហេតុដែលបណ្ដាលឲ្យមានការព្យួរកិច្ចសន្យាការងារឡើង ដោយសារតែ មានការរាតត្បាត់ខ្លាំងនៃជំងឺកូវិត១៩ នៅក្នុងប្រទេសទទួលទំនិញ ក៏ជាប្រទេសជាច្រើនទៀតទូទាំងពិភពលោក ដែលហេតុនាំឲ្យគ្មានការបញ្ជារទិញទំនិញ ពីប្រភពបរទេសធ្វើឲ្យសហគ្រាសបាត់បង់ចំណូលដែលមិនអាចផ្គត់ផ្គង់ រាល់ការចំណាយផ្សេងៗ ជាពិសេសថ្លៃពលកម្មដល់កម្មករនិយោជិកទាំងអស់បាន ។ ហេតុដូចនេះ ទើបក្រុមហ៊ុនសំរេចចិត្ត ព្យួរកិច្ចសន្យាការងារកម្មករនិយោជិក ចំនួន ២៨នាក់ ក្នុងកំឡុង ១ខែ ដោយក្រុមហ៊ុននឹងផ្ដល់ប្រាក់ឧបត្ថម្ភ ដល់កម្មករនិយោជិកក្នុងម្នាក់៣០ដុល្លាជារៀងរាល់ខែ។ ការព្យួរកិច្ចសន្យានេះនឹងចាប់ផ្ដើមពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២០នេះ រហូតដល់ថ្ងៃទី ១០ខែ មិថុនា ឆ្នាំ២០២០ ។ ការប្រជុំបានបញ្ចប់នៅវេលា ម៉ោង ០១នឹង០០ នាទី ។

កិច្ចព្រមព្រៀងនេះធ្វើឡើងដោយមានការយល់ស្របទាំងនឹងមិនមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។

ដើម្បីជាសក្ខីភាពដែលបញ្ជាក់អំពីសេចក្ដីរៀបរាប់ខាងលើនេះពិតជាត្រឹមត្រូវនឹងមិនមានការក្លែងបន្លំណាមួយ យើងខ្ញុំសូមផ្ដិតមេដៃស្ដាំ ទុកជាភ័ស្ដុតាំង។

តំណាងកម្មករនឹងប្រតិភូបុគ្គលិក

**តំណាងសហគ្រាស**

Mr.Haruhiko kakuno